បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

# ១០០ គាថា

កម្មសិទ្ធិ [illegible] ពុទ្ធសាសនបណ្ឌិត្យ
បោះពុម្ព ទី ២
ចំនួន ២.០០០ ក្បាល

INSTITUT BOUDDHIQUE

ព.ស. ២៥១៣

២៤៧.
១៥

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# ១០០គាថា

INSTITUT BOUDDHIQUE

ព.ស. ២៥១៣

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

២៤៧.១៥

# ១០០ គាថា

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
បោះពុម្ពគ្រាទី ២
ចំនួន ២.០០០ ច្បាប់

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE
LIBRARY
BUDDHIST INSTITUTE
២០១៤/០២

ព.ស. ២៥១៣

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្ស៊ូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

www.budinst.gov.kh        www.elibraryofcambodia.org
www.elibraryofcambodia.org

៙ យើងយល់ឃើញថាជាការមានប្រយោជន៍ណាស់ ដល់ខេមរជាតិ ទាំងអ្នកបួស ទាំងគ្រហស្ថ ទាំងចាស់ ទាំងក្មេង ដែលបានសៀវភៅពាក្យសុភាសិតយ៉ាងល្អ ដើម្បីនឹងដាស់តឿនស្មារតី និងញុំាងចិត្តខ្លួនឲ្យត្រឹមត្រូវតាមគន្លងធម៌ ។

ដោយហេតុនេះហើយបានជាយើងទូលសុំ ឲ្យលោកព្រះគ្រូវិមល-បញ្ញា អ៊ុម-ស៊ូរ និងលោកព្រះគ្រូសង្ឃវិជ្ជា ពាត ស្រង់យកសុភាសិតទាំងឡាយដែលបានប្រទះឃើញ វេលាដែលកំពុងមើលគម្ពីរដីកាផ្សេងៗ ដើម្បីនឹងប្រមូលយកមកបោះពុម្ពជាសៀវភៅឡើង ក៏គាថាទាំងប៉ុន្មានដែលមានក្នុងសៀវភៅនេះ បានដកយកពីគម្ពីរផ្សេង ៗ ដែលលោកបានមើល ។

ជនណាដែលមានសៀវភៅនេះជាប់នឹងខ្លួន នោះអាចសម្គាល់ឃើញថា ខ្លួនមិនមែនជាមនុស្សឯកឯងឥតទីពឹងឡើយ ព្រោះថា នៅវេលាដែលយកសៀវភៅនេះ មកបើកមើល ទោះត្រូវត្រង់ទំព័រណាក៏ដោយនឹងប្រទះឃើញគាថាណាមួយ ហើយក៏នឹងកើតសេចក្តីពេញចិត្ត ហាក់ដូចជាបានគ្រូអាចារ្យ ឬកល្យាណមិត្តម្នាក់មកនៅជិតខ្លួន ៕-

ស៊ុយសានការប៊ុំឡែស

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# បរិយាយដើម

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# អត្ថកថា

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ

តិណ្ណំ អញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ

៙ បណ្ឌិត បើដឹងខ្លួនថាជាទីស្រឡាញ់ គប្បីរក្សាខ្លួននោះ ទុកឲ្យល្អ គប្បីរក្សាខ្លួនក្នុងវ័យទាំង ៣ វ័យណាមួយ កុំខានឡើយ ។ ៚

---

អត្តានមេវ បឋមំ បដិរូបេ និវេសយេ

អថញ្ញមនុសាសេយ្យ ន កិលិស្សេយ្យ បណ្ឌិតោ

៙ បណ្ឌិតគប្បីតម្កល់ខ្លួនក្នុងគុណសម្បត្តិដ៏សមគួរជាមុនសិន ហើយ សឹមប្រៀនប្រដៅនូវអ្នកដទៃជាខាងក្រោយ (ធ្វើយ៉ាងនេះ) នឹងមិន លំបាកឡើយ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

អត្តានញ្ចេ តថា កយិរា យថញ្ញមនុសាសតិ

សុទន្តោ វត ទមេថ អត្តា ហិ កិរ ទុទ្ទមោ

៙ បុគ្គល បើប្រៀនប្រដៅអ្នកដទៃយ៉ាងណា ត្រូវធ្វើនូវខ្លួនឲ្យបានយ៉ាងនោះដែរ, អ្នកដែលទូន្មានខ្លួនល្អហើយ គួរនឹងទូន្មានអ្នកដទៃបាន, ព្រោះថា ខ្លួនគឺបុគ្គលទូន្មានដោយកម្រពេកណាស់ ៚

អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា

អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ

៙ ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃដូចម្ដេចឡើយនឹងជាទីពឹងខ្លួនបាន, ព្រោះបុគ្គលមានខ្លួនដែលហ្វឹកហ្វឺនល្អហើយ តែងបាននូវទីពឹងដែលគេបានដោយកម្រ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

អត្តនា ហិ កតំ បាបំ អត្រជំ អត្តសម្ភវំ
អភិមត្ថតិ ទុម្មេធំ វជិរំវម្ហយំ មណឹ

៙ បាបដែលខ្លួនបានធ្វើទុកហើយ រមែងកើតក្នុងខ្លួន មានខ្លួនជាដែន ជាទីកើតឡើង (នៃបាប) តែងញាំញីនូវមនុស្សឥតប្រាជ្ញា ដូចជាពេជ្រ សម្រាប់កាត់នូវត្បូងមណីដែលកើតក្នុងថ្មនោះឯង ៚

—

យស្ស អច្ចន្តទុស្សីល្យំ មាលុវា សាលមិវោត្ថតំ
ករោតិ សោ តថត្តានំ យថា នំ ឥច្ឆតី ទិសោ

៙ ភាវៈនៃបុគ្គលឯណាជាអ្នកទ្រុស្តសីល តែងគ្របសង្កត់ (នូវខ្លួនឯង) ដូចជាវល្លិ៍ព្រៃ តែងរឹតរួតគ្របសង្កត់នូវដើមរាំងដូច្នោះ, អ្នកនោះរមែងធ្វើខ្លួនដូចជាចោរ ប្រាថ្នានឹងទ្រុស្តនូវបុគ្គលនោះដូច្នោះឯង ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សុករានិ អសាធូនិ អត្តនោ អហិតានិ ច
យំ វេ ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ

៙ កម្មទាំងឡាយណា ដែលមិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មទាំងឡាយនោះ គឺគេធ្វើបានដោយងាយ, កម្មណា ដែលជាប្រយោជន៍ផង ល្អផង កម្មនោះ គឺគេធ្វើបានដោយក្រក្រៃពេក ៚

អត្តនា វ កតំ បាបំ អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ
សុទ្ធិអសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ

៙ ធ្វើបាបដោយខ្លួនឯង រមែងសៅហ្មងដល់ខ្លួនឯងវិញ, មិនធ្វើបាបដោយខ្លួនឯងហើយ តែងបរិសុទ្ធស្អាតដល់ខ្លួនឯង, សេចក្ដីបរិសុទ្ធនិងមិនបរិសុទ្ធ តែងកើតចំពោះខ្លួនឯង ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ
អត្តទត្ថមភិញ្ញាយ សទត្ថប្បសុតោ សិយា

៙ បុគ្គល កុំគប្បីធ្វើនូវប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍អ្នកដទៃច្រើន, បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួននោះកុំខាន ៕—

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# ចិត្តកថា

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ
ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ

៙ អ្នកមានប្រាជ្ញា រមែងធ្វើចិត្តដែលញាប់ញ័រ រវេងរវោង រក្សាបានដោយកម្រ ហាមដោយកម្រ ឲ្យជាចិត្តត្រង់បាន ដូចជាជាងសរ ពត់នូវកូនសរឲ្យត្រង់នោះឯង ៚

—៚០៚—

វារិជោវ ថលេ ខិត្តោ ឱកមោកត ឧព្ភតោ
បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ

៙ ចិត្តនេះ ដែលបុគ្គលលើកឡើងហើយចាកអាល័យ គឺកាមគុណ បោះទៅលើគោកពោលគឺវិបស្សនាកម្មដ្ឋាន ដើម្បីនឹងលះបង់នូវវិស័យនៃមារ ក៏តែងញាប់ញ័រ ដូចជាត្រីដែលព្រានត្រីចាប់ឡើងចាកទីនៅគឺទឹក បោះទៅលើគោក តែងញាប់ញ័រដូច្នោះឯង ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ
ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ

៙ សេចក្តីទូន្មានចិត្ត ដែលស្រាល ដែលគេឃ្លាំងឃាត់បានដោយកម្រ មានប្រក្រតីធ្លាក់ចុះទៅក្នុងអារម្មណ៍ណាមួយបានហើយ ក៏ជាគុណញ៉ាំងប្រយោជន៍ឲ្យសម្រេច, ចិត្តដែលហ្វឹកហ្វឺនបានហើយនោះ តែងនាំយកនូវសេចក្តីសុខមកឲ្យ ៚

សុទុទ្ទសំ សុនិបុណំ យត្ថកាមនិបាតិនំ
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ

៙ អ្នកមានប្រាជ្ញា គួររក្សាចិត្ត ដែលគេឃើញបានដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីលង់ចុះក្នុងអារម្មណ៍ណាមួយ, ចិត្តដែលគេរក្សាបានហើយនោះ តែងនាំយកនូវសេចក្តីសុខ មកឲ្យគេមិនខានឡើយ ៚

www.budinst.gov.kh www.elibraryofcambodia.org

ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ
យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា

ខ អ្នកទាំងឡាយឯណា នឹងសង្រួមចិត្ត ដែលមិនមានសរីរៈ ដែលត្រាច់ទៅម្នាក់ឯង តែងទទួលអារម្មណ៍ក្នុងទីឆ្ងាយ មានគូហាគឺមហាភូតរូប ៤ ជាទីអាស្រ័យនៅបាន, អ្នកទាំងនោះឯង នឹងផុតចាកចំណងនៃមារ មិនខានឡើយ ៚

អនវដ្ឋិតចិត្តស្ស សទ្ធម្មំ អវិជានតោ
បរិប្លវប្បសាទស្ស បញ្ញា ន បរិបូរតិ

ខ បញ្ញា តែងមិនមានដល់មនុស្ស ដែលមានចិត្តមិនមាំមួន មិនដឹងនូវព្រះសទ្ធម្ម មានសេចក្តីជ្រះថ្លាអណ្តែតទៅ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

អនវស្សុតចិត្តស្ស អនន្វាហតចេតសោ

បុញ្ញបាបបហីនស្ស នត្ថិ ជាគរតោ ភយំ

៙ ភ័យ តែងមិនមានដល់មនុស្ស ដែលមានចិត្តដែលរាគៈមិនប្រឡាក់ហើយ មានចិត្តដែលទោសៈមិនទ្វាំងទ្វប់ហើយ មានបុណ្យនិងបាប បន្សាត់ចោលហើយ ជាអ្នករឭកដឹងខ្លួន ៚

កុម្ភូបមំ កាយមិមំ វិទិត្វា

នគរូបមំ ចិត្តមិទំ ឋបេត្វា

យោធេថ មារំ បញ្ញាវុធេន

ជិតញ្ច រក្ខេ អនិវេសនោ សិយា

៙ បុគ្គល គប្បីដឹងច្បាស់នូវកាយនេះថាដូចជាឆ្នាំង គប្បីបិទឃាត់នូវចិត្តនេះ ឲ្យដូចជាបិទទ្វារនគរ គប្បីសម្លាប់នូវមារដោយអាវុធគឺបញ្ញា គប្បីរក្សាទុកនូវវិបស្សនាដែលខ្លួនបានហើយថ្មីៗកុំឲ្យវិនាសបង់ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

អនវស្សុតចិត្តស្ស អនន្វាហតចេតសោ
បុញ្ញបាបបហីនស្ស នត្ថិ ជាគរតោ ភយំ

៧ ភ័យ តែងមិនមានដល់មនុស្ស ដែលមានចិត្តដែលរាគៈមិនប្រឡាក់ហើយ មានចិត្តដែលទោសៈមិនខ្ទាំងខ្ទប់ហើយ មានបុណ្យនិងបាបបន្សាត់ចោលហើយ ជាអ្នកភ្ញាក់ជានិច្ច ៕

---

កុម្ភូបមំ កាយមិមំ វិទិត្វា
នគរូបមំ ចិត្តមិទំ ឋបេត្វា
យោធេថ មារំ បញ្ញាវុធេន
ជិតញ្ច រក្ខេ អនិវេសនោ សិយា

៨ បុគ្គល គប្បីដឹងច្បាស់នូវកាយនេះថាដូចជាឆ្នាំង គប្បីបិទឃាត់នូវចិត្តនេះ ឲ្យដូចជាបិទទ្វារនគរ គប្បីសម្លាប់នូវមារដោយអាវុធគឺបញ្ញា គប្បីរក្សាទុកនូវវិបស្សនាដែលខ្លួនបានហើយប្រឹងៗកុំឲ្យវិនាសបង់ ៕

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# បញ្ញាគថា

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សុស្សូសា សុតវឌ្ឍនា បញ្ញាយ វឌ្ឍនំ សុតំ
បញ្ញាយ អត្ថំ ជានត្តិ ញាតោ អត្ថោ សុខាវហោ

៙ សេចក្ដីដឹងនិងសេចក្ដីចម្រើន ព្រោះតែការស្ដាប់មាំ, សេចក្ដីដឹងតែងចម្រើនឡើង ព្រោះតែប្រាជ្ញា, អាស្រ័យនូវប្រាជ្ញា ទើបដឹងច្បាស់នូវប្រយោជន៍, ប្រយោជន៍ដែលដឹងហើយ នឹងនាំយកគ្រឿងសុខមកឲ្យ ។

---

អនាគតំ ភយំ ទិស្វា ទូរតោ បរិវជ្ជយេ
អាគតញ្ច ភយំ ទិស្វា អភីតោ ហោតិ បណ្ឌិតោ

៙ បណ្ឌិត ឃើញនូវភ័យដែលមិនទាន់មកដល់ គប្បីវៀរចេញអំពីឆ្ងាយ, លុះភ័យមកប្រទះហើយ តែងមិនតក់ស្លុតឡើយ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

លោភំ កោធំ មទំ មានំ តណ្ហំ ឥស្សំ បមត្តកំ

សោណ្ឌំ និទ្ទា លុកំ មក្ខំ មច្ឆេរញ្ច ជហេ ពុទ្ធោ

៙ សេចក្តីជាប់ជំពាក់ ក្រោធ ស្រវឹង ប្រកាន់ខ្លួន ខ្ជិល ប្រណែន ប្រហែសធ្វេស អ្នកលេង ផឹកច្រើន លុបគុណគេ កំណាញ់ ទាំងអស់នេះ អ្នកមានបញ្ញាគួរលះចោលចេញ ៚

សទ្ធា ហិរិ ច ឱត្តប្បំ ពាហុសច្ចំ វីរំ សតិ

បញ្ញា ច សត្ត ធម្មេតិ សម្បន្នោ បណ្ឌិតោ មតោ

៙ សេចក្តីជឿ ខ្មាសបាប ខ្លាចក្រែងបាប កិរិយាស្តាប់ច្រើន ទំសង្វាត ស្មារតី និងបញ្ញា, អ្នកដែលដល់ព្រមនូវធម៌ល្អ ៧ យ៉ាងនេះ ហៅថា បណ្ឌិត ៚

www.budinst.gov.kh www.elibraryofcambodia.org

ទិដ្ឋេ ធម្មេ ច យោ អត្ថោ
យោ ចត្ថោ សម្បរាយិកោ
អត្ថាភិសមយា ធីរោ
បណ្ឌិតោតិ បវុច្ចតិ

៙ ប្រយោជន៍ឯណា ដែលជាប្រយោជន៍ក្នុងបច្ចុប្បន្ននេះ ប្រយោជន៍ឯណា ដែលជាប្រយោជន៍ក្នុងបរលោកខាងមុខ, បុគ្គល ដែលលោកហៅថាបណ្ឌិតមានប្រាជ្ញាខ្ជាប់ខ្ជួន ព្រោះកិរិយាដឹងនូវប្រយោជន៍ ( ទាំងពីរយ៉ាងនោះឯង ) ៚

ភូបាលោ បណ្ឌិតោ ចាបិ នេវ តុល្យោ កុទាចនំ
សទេសេ បូជិតោ រាជា ពុទ្ធោ សព្វត្ថ បូជិតោ

៙ ម្ចាស់ផែនដីនិងបណ្ឌិត មិនប្រៀបស្មើគ្នាជានិច្ចគ្រប់កាលមិនបាន ព្រោះម្ចាស់ផែនដីមានមនុស្សបូជាតែក្នុងប្រទេសរបស់ព្រះអង្គ ឯបណ្ឌិតមានមនុស្សបូជាក្នុងទីគ្រប់ដំបន់ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

បណ្ឌិតស្ស បសំសាយ ទណ្ឌោ ពាលេន និយតេ
បណ្ឌិតោ បណ្ឌិតេនេវ វណ្ណិតោ វ សុវណ្ណិតោ

៙ មនុស្សពាល ឈ្មោះថានាំនូវអំណាចដល់បណ្ឌិត ដោយសេចក្តីសរសើរ, បណ្ឌិត គឺបណ្ឌិតផងគ្នាតែងសរសើរ ហើយសរសើរដោយល្អ ៚

អត្តា យទិ ឯកេន វិនិតេន មហាជនា
វិនយំ យន្តិ សព្វេបិ កោធំ នាសេយ្យ បណ្ឌិតោ

៙ ថាបើ ទូន្មានខ្លួនឯងមួយបានហើយ មហាជនទាំងឡាយទាំងពួង នឹងប្រព្រឹត្តទៅតាមខ្លួននោះ, បណ្ឌិត គប្បីរំងាប់នូវសេចក្តីក្រោធចេញឲ្យស្រឡះ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សរីរស្ស គុណានញ្ច ទូរមច្ចន្តមន្តរំ
សរីរំ ខណវិទ្ធំសិ គុណា តុ កប្បដ្ឋាយិនោ

៙ សរីរៈរាងកាយនិងគុណ តែងមានការឃ្លាតឆ្ងាយជាទីបំផុត, សរីរៈ តែងបែកទៅដោយឆាប់រហ័ស, ឯគុណវិញ តាំងនៅអស់កប្ប ៚—

—៚០៙—

អត្ថំ មហន្តមាបជ្ជំ វិជ្ជំ សម្បត្តិមេវ ប
បវេយ្យ មានត្ថទ្ធោ បណ្ឌិតោ សោ បវុច្ចតិ

៙ អ្នកដែលបានដល់នូវប្រយោជន៍ធំ គឺវិជ្ជានិងសម្បត្តិ តែជាអ្នកមិនអក្អឹងដោយមានះទេ, អ្នកនោះឯង លោកហៅថាបណ្ឌិត ៚—

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

នាលព្ភមភិបត្ថេន្តិ នដ្ឋម្បិ ន ប សោចរេ
វិបត្យញ្ច ន មុយ្ហន្តិ យេន ភាតេវ បណ្ឌិតោ

ឱ វត្ថុដែលមិនគួរបាន ក៏មិនប្រាថ្នាឡើយ, វត្ថុដែលវិនាសទៅ ក៏មិនសោកស្តាយឡើយ, ដល់នូវវិបត្តិ ក៏មិនវង្វេងឡើយ, ជនពួកនេះ ជាបណ្ឌិតដោយពិត ៚

—⁂—

គណ្ឋិដ្ឋានេ ឯកបទេ នាតិមញ្ញេយ្យ បណ្ឌិតោ
កិមក្កោ វេឡុបត្តាវោ តិមហាទីបភាណុទោ

ឱ បទនីមួយ ដែលអ្នកប្រាជ្ញរៀបក្រងទុក, បណ្ឌិតកុំគប្បីមើលងាយឡើយ, ព្រះអាទិត្យដែលភ្លឺស្វាង រហូតមហាទ្វីប ៣ ម្តេចឡើយក៏នឹងក្លាយជាកំណាត់ឫស្សីទៅបាន ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

គុណទោសេសុ នេកេន អត្ថិ កោ ច វិវជ្ជិតោ

សុខុមាលបទុមស្ស ឆទ្ឡំ ភវតិ កក្ខឡំ

៙ អ្នកណាមួយ នឹងវៀរចាកគុណនិងទោសដោយចំណែកមួយ ពុំបានឡើយ, ប៉ុនអម្បូលផ្កាឈូកដែលជារបស់ទន់ល្អ ម្តេចក៏គង់មានទងជារបស់គ្រោតគ្រាតដែរ ៚—

—៚៙៚—

សុមហន្តានិ សត្ថានិ

ធារយន្តា ពហុស្សុតា

ឆេទាយោ សំសយន្តាន-

ន្តុ កិលិស្សន្តិ លោភមោហិតា

៙ អ្នកដែលមានសេចក្តីចេះដឹងច្រើន ចងចាំទ្រទ្រង់នូវគម្ពីរទាំងឡាយដ៏ធំទូលាយ ហើយជាអ្នកអាចកាត់នូវសេចក្តីសង្ស័យទាំងឡាយបាន លុះផល់សេចក្តីលោភមកគ្របសង្កត់បិទបាំងឲ្យងងឹតមុខ ក៏ប្រែជាសៅ-ហ្មងទៅបាន ៚—

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ទោសំបិ សគុណោ ទិស្វា គុណាភាវី វិទន្តិ តំ
ន លោកោ វិជ្ជមានម្បិ ចន្ទេ បស្សតិ លញ្ឆនំ(១)

៙ មនុស្សពាលនិយាយថ្លែងចំពោះតែគុណ បើទុកជាឃើញទោសខ្លួនក្នុងគុណរបស់ខ្លួន ក៏មិននិយាយថ្លែងឡើយ (ដូចជា) ស្នាមក្នុងវង់ព្រះចន្ទ្រ បើទុកជាមាន ក៏សត្វលោកឥតមានឃើញឡើយ ៚

---

១ ច្បាប់ខ្លះថា លក្ខណំ តែបានសង្កេតក្នុងទីឯទៀតប្រាកដជាលញ្ឆនំ “ស្នាមឬគ្រឿងសម្គាល់” ។

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សកឹបិ វិញ្ញូ ចិរេន ករោតិ សហសង្គមំ

អត្តត្ថញ្ច បរត្ថញ្ច និព្វានត្ថំ សុខំ លភេ

៙ អ្នកប្រាជ្ញ សូម្បីជួបជុំតែម្តងដោយកាលវែង ក៏គង់បានប្រយោជន៍ខ្លួនផងប្រយោជន៍អ្នកដទៃផង ហើយនិងសេចក្តីសុខមានព្រះនិព្វានជាទីបំផុត ៚

—៚០៚—

បណ្ឌិតោ អបុដ្ឋោ ភេរី បជ្ជុន្នោ ហោតិ បុច្ឆិតោ

ពាលោ បុដ្ឋោ អបុដ្ឋោបិ ពហុំ វិកត្ថកោ សទា

៙ បណ្ឌិត បើគេមិនសួរ ដូចជាស្គរដែលគេមិនគោះ លុះតែមានគេសួរ ទើបបង្អុរនូវភ្លៀង គឺមធុរកថា ឲ្យគេស្តាប់, ជនពាល ទោះគេសួរក្តី គេមិនសួរក្តី ក៏តែងនិយាយបែមពិដែលរាវរាល់ពេល ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

គុណសម្បន្នលង្ការោ សព្វសត្តហិតាវហោ

បរត្ថំ ន បរេយ្យ កុតោ សោ បណ្ឌិតោ ភវេ

៙ អ្នកបរិបូណ៌ដោយគុណសម្បត្តិជាគ្រឿងប្រដាប់ ជាអ្នកអាចនាំមកនូវប្រយោជន៍ដល់សត្វទាំងពួងបាន តែបើមិនប្រព្រឹត្តយកប្រយោជន៍ទាំងនោះឲ្យបានដល់ខ្លួននិងអ្នកដទៃទេ អ្នកនោះឯងនឹងបានឈ្មោះថាបណ្ឌិតដូចម្ដេចបាន ៚

---

សបរត្ថំ បរេ ធីរោ សក្កោន្តោ សកំ បរេ

តម្បិ ចេវ អសក្កោន្តោ បាបាត្តានំ វិយោជយេ

៙ អ្នកប្រាជ្ញ គប្បីប្រព្រឹត្តនូវប្រយោជន៍ខ្លួននិងប្រយោជន៍អ្នកដទៃ, បើមិនអាចធ្វើនូវប្រយោជន៍ទាំងពីរនោះបានទេ គប្បីប្រព្រឹត្តតែប្រយោជន៍របស់ខ្លួនចុះ, បើប៉ុណ្ណោះហើយនៅតែមិនអាចទៀត គប្បីនាំខ្លួនចេញចាកបាបឲ្យបាន ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សព្វំ សុណាតិ សោតេន សព្វំ បស្សតិ ចក្ខុនា

ន ច ទិដ្ឋំ សុតំ ធីរោ សព្វុជ្ឈិតុមរហតិ

២ គេស្តាប់នូវសំឡេងគ្រប់យ៉ាងបាន ដោយត្រចៀក, គេឃើញនូវរូបគ្រប់យ៉ាងបាន ដោយភ្នែក, តែឯអ្នកប្រាជ្ញ មិនត្រូវប្រាថ្នានូវរូប ដែលខ្លួនបានឃើញ និងសំឡេងដែលខ្លួនបានឮគ្រប់យ៉ាងនោះឡើយ ៚

ចក្ខុមាស្ស យថាអន្ធោ សោត្វា ពធិរោ យថា

បញ្ញាវិបិ យថាមូគោ ពលវា ទុព្វលោរិវ

អថ អត្ថេ សមុប្បន្នេ សយេយ្យ មតសាយិតំ

៣ មនុស្សខ្លះ មានភ្នែកដូចជាភ្នែកខ្វាក់ មានត្រចៀកដូចជាត្រចៀកថ្លង់ មានបញ្ញាដូចជាមនុស្សគ មានកម្លាំងដូចជាមនុស្សខ្សោយ, កាលបើប្រយោជន៍ដល់ព្រមហើយ ខ្លួនឯងទៅជាដេក ដូចជាមនុស្សស្លាប់ទៅវិញ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ន សា សភា យត្ថ ន សន្តិ សន្តោ

សន្តោ ន តេ យេ ន វទន្តិ ធម្មំ

រាគញ្ច ទោសញ្ច បហាយ មោហំ

ធម្មំ ភណន្តា វ ភវន្តិ សន្តោ

៣ ទីប្រជុំណាមិនមានសប្បុរស ទីនោះមិនឈ្មោះថាទីប្រជុំឡើយ ជនណាមិនពោលនូវធម៌ ជននោះមិនឈ្មោះថាសប្បុរសឡើយ អ្នកដែលលះនូវរាគៈទោសៈមោហៈបាន និងអ្នកពោលនូវធម៌ត្រូវនោះ លោកហៅថាសប្បុរសបាន ៚

បរទារំ ជនេត្តិំវ លេណ្ឌុំវ បរសន្តកំ

អត្តាវ សព្វសត្តានំ យោ បស្សតិ ស បណ្ឌិតោ

២ អ្នកឯណាឃើញភរិយាអ្នកដទៃ តាំងចិត្តស្មើដូចឃើញម្ដាយបង្កើត, ឃើញសម្បត្តិអ្នកដទៃ ក៏តាំងចិត្តស្មើដូចឃើញដុំដី, ឃើញសត្វទាំងពួង តាំងចិត្តស្មើដូចខ្លួន, អ្នកនោះ ជាបណ្ឌិតពិតមែន ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សឋេន មិត្តំ កលុសេន ធម្មំ
បរោ បតាបេន សមិទ្ធភាវំ
សុខេន វិជ្ជំ ផរុសេន នារឹ
ឥច្ឆន្តិ យេ តេ ន ច បណ្ឌិតា វេ

៙ ជនណា ប្រាថ្នានូវមិត្រដោយវិធីអួតអាង ប្រាថ្នានូវធម៌ដោយប្រើវិធីលាមក ប្រាថ្នានូវប្រយោជន៍ដោយវិធីញុំាងគេឲ្យក្តៅក្រហាយ ប្រាថ្នានូវវិជ្ជាចំណេះដោយវិធីស្រួលខ្លួន ប្រាថ្នានូវស្រីក្រមុំដោយវិធីពោលពាក្យអាក្រក់, ជនទាំងនោះ មិនមែនជាបណ្ឌិតឡើយ ៚

យថាបិ អង្គសម្ភារា ហោតិ សទ្ទោ រថោ ឥតិ
ឯវំ ខន្ធេសុ សន្តេសុ ហោតិ សត្តោតិ សម្មុតិ

៙ គ្រឿងប្រដុងទាំងឡាយនៃរថមកប្រជុំព្រមហើយ លោកហៅថារទេះដូចម្តេចមិញ, ខន្ធទាំង ៥ របស់សត្វមានព្រមហើយ លោកក៏សន្មតហៅថាមនុស្ស ថាសត្វ ដូច្នោះឯង ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សទ្ធាយ តរតិ ឱឃំ  អប្បមាទេន អណ្ណវំ
វីរិយេន ទុក្ខមច្ចេតិ  បញ្ញាយ បរិសុជ្ឈតិ

៙ គេឆ្លងនូវអន្លង់បាន ដោយសារសទ្ធា, គេឆ្លងនូវមហាសមុទ្របាន ដោយសារការប្រយ័ត្ន, គេកន្លងនូវសេចក្ដីទុក្ខបានដោយសារព្យាយាម, គេបរិសុទ្ធផុតគ្រឿងសៅហ្មងបាន ដោយសារប្រាជ្ញាយល់ត្រូវ ។–

ចត្តារោ មគ្គេ បដិបន្នោ ចត្តារោ វ ផលេដ្ឋិតោ
ឯស សង្ឃោ ឧជុភូតោ បញ្ញាសីលសមាហិតោ

៙ អ្នកណាមានចិត្តត្រង់ ប្រកបដោយសីល សមាធិ បញ្ញា ប្រតិបត្តិក្នុងមគ្គ ៤ តាំងនៅក្នុងផល ៤, អ្នកនោះឯង លោកហៅថាសង្ឃ ។–

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

វិបុលោ រាជគហីយានំ គិរិសេដ្ឋោ បវុច្ចតិ
សេតោ ហិមវតំ សេដ្ឋោ អាទិច្ចោ អឃគាមិនំ

៙ ភ្នំវិបុល ប្រសើរជាងភ្នំទាំងអស់ក្នុងដំបន់ក្រុងរាជគ្រឹះ, ភ្នំក្រៃលាស ប្រសើរជាងភ្នំទាំងអស់ក្នុងព្រៃហេមពាន្ត, ចំណែកព្រះអាទិត្យ រុងរឿងជាងវត្ថុទាំងអស់ដែលមានឰដ៏អាកាស ៚

សមុទ្ទោ នទីនំ សេដ្ឋោ នក្ខត្តានញ្ច ចន្ទិមា
សទេវកស្ស លោកស្ស ពុទ្ធោ អគ្គោ បវុច្ចតិ

៙ មហាសមុទ្រ ធំជ្រៅជាងស្ទឹងទាំងអស់, ព្រះចន្ទ ប្រសើរជាងផ្កាយទាំងអស់, ព្រះសព្វញ្ញុពុទ្ធ រុងរឿងបំផុតជាងទេវតានិងមនុស្ស ក្នុងលោក ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

រាគោ ទោសោ ច មោហោ ច
មានោ លុទ្ធោ ច អាលសោ
ឯកបិន្តិតោ ពាណោវ ឯតេ អត្ថំ វិនាសយ

៙ មនុស្ស ប្រកបដោយតម្រេក ដោយសេចក្ដីក្រោធ ដោយសេចក្ដីល្ងង់ ដោយកិរិយាកាន់ខ្លួន ដោយអំពើអាក្រក់ ដោយសេចក្ដីខ្ជិល ដោយគំនិតតែម្នាក់ឯង ដោយខ្លួនពាល, មនុស្សទាំង ៨ ពួកនេះ នឹងគិតសេចក្ដីជ្រាលជ្រៅមិនឃើញឡើយ ៚

រាគោ ទោសោ ច មោហោ ច ភីរុកោ អាមិសគរុ
ឥត្ថី សោណ្ឌី ច មណ្ឌកោ ឆរមោ ភវតិ ទារកោ

៙ មនុស្សប្រកបដោយតម្រេកច្រើន ដោយសេចក្ដីក្រោធច្រើន ដោយភាន់ច្រឡំច្រើន ដោយខ្លាចច្រើន ដោយធ្ងន់ក្នុងអាមិស មនុស្សស្រី អ្នកលេងសុរា អ្នកតែងខ្លួន កូនក្មេង, មនុស្សទាំង ៩ ពួកនេះ មិនអាចនឹងចាំទុកនូវសេចក្ដីសុខុមគម្ភីរភាព គឺសេចក្ដីដែលល្អិត ដែលជ្រាលជ្រៅបានឡើយ ៚

www.budinst.gov.kh www.elibraryofcambodia.org

វិយេន យសបរិបុប្ផាយ តិត្ថាភិសេន យោនិសោ

សាកច្ឆា ស្នេហបរិសេន បដិរូបវិសតាយ ភិ

ឳ ហេតុដែលកើតប្រាជ្ញា មាន ៨ យ៉ាងគឺ មនុស្សមានវ័យល្អ ១ អាស្រ័យសប្បុរស ១ ទំនាក់ទំនងល្អ ១ មិនសេពគប់ទុរជន ១ ពោលពិចារណា ១ និយាយតែអំពីអត្ថនិងធម៌ ១ មានចិត្តស្នេហាក្នុងធម៌អាថ៌ ១ នៅក្នុងប្រទេសដ៏សមគួរ ១ ៚

—៚៙៚—

នាភិនន្ទាមិ មរណំ នាភិនន្ទាមិ ជីវិតំ

កាលញ្ច បដិកង្ខាមិ និព្វិសំ ភតកោ យថា

៙ (ព្រះសារីបុត្តត្ថេរលោកពោលថា) ខ្ញុំមិនត្រេកអរចំពោះត្រង់សេចក្តីស្លាប់ក៏ទេ មិនត្រេកអរចំពោះត្រង់ការរស់នៅក៏ទេ ខ្ញុំរង់ចាំតែពេលវេលា ដូចជាពួកស៊ីឈ្នួលរង់ចាំតែរង្វាន់ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ពាឈភថា

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ
ន សោ ធម្មំ វិជានាតិ ទព្វិ សូបរសំ យថា

៥ . មនុស្សពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់ ១ ជីវិតក្តី ក៏ឥតបានដឹងធម៌អាថ៌អ្វីឲ្យច្បាស់លាស់ឡើយ ដូចគ្នានឹងវែកដែលមិនដឹងរសសម្ល ៚

ទុជ្ជនោ វជ្ជនីយោ វ វិជ្ជាយាលង្កតោបិ ចេ
មណិនាលង្កតោ សត្តោ សប្បោ កឹ ន ភយំ ករោ

៦ មនុស្សទុរជន គឺជនចិត្តអាក្រក់ បើទុកជាប្រដាប់ហើយដោយវិជ្ជា ក៏គួរអ្នកទាំងឡាយគប្បីវៀរដោយពិត, សត្វមានអាសិរពិស បើទុកជាប្រដាប់ហើយ ដោយកែវមណីដូចម្តេច ក៏វាគង់នឹងធ្វើភ័យឲ្យកើតឡើងបាន ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សប្បោ ទុដ្ឋោ ខលោ ទុដ្ឋោ សប្បា ទុដ្ឋតរោ ខលោ
មន្តោសធេហិ សោ សប្បោ ខលោ កេនុបសម្មតិ

៙ សត្វពស់ជាសត្វប្រទុស្ត មនុស្សពាលក៏ជាអ្នកប្រទុស្ត តែមនុស្សពាលប្រទុស្តរកក្រៃលែងជាងពស់ ព្រោះពិសពស់អាចរម្ងាប់ដោយមន្តនិងថ្នាំបាន ឯពិសមនុស្សពាលវិញនោះ តើនឹងធ្វើឲ្យរម្ងាប់បានដោយវិធីដូចម្តេច ៚

៚៙៚

យោ ពាលោ មញ្ញតិ ពាល្យំ
បណ្ឌិតោ វាបិ តេន សោ
ពាលោ ច បណ្ឌិតមានី
ស្វេ ពាលោតិ វុច្ចតិ

៙ អ្នកណា ជាមនុស្សពាល ហើយដឹងនូវភាវៈនៃខ្លួនថាជាពាល អ្នកនោះនឹងត្រឡប់ទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួនថាជាពាលនោះ, ម្យ៉ាងទៀត អ្នកណាជាមនុស្សពាល មានមានះប្រកាន់ថាខ្លួនជាបណ្ឌិត អ្នកនោះលោកហៅថាជាមនុស្សពាលដោយពិត ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

មធុវា មញ្ញតី ពាលោ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ អថ ទុក្ខំ និគច្ឆតិ

៥ បាបមិនទាន់ឲ្យផលត្រឹមណា មនុស្សពាល តែងសម្គាល់នូវបាបថាដូចជាទឹកឃ្មុំត្រឹមនោះ លុះតែកាលណាបាបឲ្យផល មនុស្សពាលទើបប្រទះនូវសេចក្ដីទុក្ខ ក្នុងកាលនោះ ៚

———

បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ អថ បាបានិ បស្សតិ

៦ បាបមិនទាន់ឲ្យផលត្រឹមណា មនុស្សបាប ក៏នៅឃើញតែសេចក្ដីចម្រើនត្រឹមនោះ លុះតែកាលណា បាបឲ្យផល មនុស្សបាប ទើបឃើញនូវបាប ក្នុងកាលនោះ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

មាវមញ្ញេថ បាបស្ស ន មន្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
បូរតិ ពាលោ បាបស្ស ថោកំ ថោកម្បិ អាចិនំ

៙ បុគ្គល កុំគប្បីមើលងាយនូវបាប ថាបាបបន្តិចបន្តួច នឹងមិនមកដល់ គឺថា មិនឲ្យផលនោះឡើយ, សូម្បីក្អមទឹករមែងពេញបាន ដោយការតំណក់ទឹកដែលធ្លាក់ចុះ, មនុស្សពាលដែលសន្សំនូវបាប ទោះបីធ្វើបន្តិចម្តង ១ ក៏គង់តែពេញដោយបាប ៚

—៚—

យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ
សុទ្ធស្ស បោសស្ស អនង្គណស្ស
តមេវ ពាលំ បច្ចេតិ បាបំ
សុខុមោ រជោ បដិវាតំវ ខិត្តោ

៙ មនុស្សពាលណា ប្រទុស្តនឹងជនដែលមិនបានប្រទុស្ត ជាអ្នកបរិសុទ្ធ ឥតមានកិលេសធម៌ បាបកម្មត្រឡប់ទៅផលដល់មនុស្សពាលនោះវិញ ដូចជាធូលីដ៏ល្អិតដែលគេបាចសាចទៅកាន់ទីច្រាសខ្យល់ ។

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

អថ បាបានិ កម្មានិ    ករំ ពាលោ ន ពុជ្ឈតិ
សេហិ កម្មេហិ ទុម្មេធោ អគ្គិទឌ្ឍោវ តប្បតិ

៙ មនុស្សពាលឥតប្រាជ្ញា កាលដែលកំពុងធ្វើនូវបាបកម្មទាំងឡាយ រមែងមិនដឹងខ្លួនទេ លុះដល់ខាងក្រោយ មនុស្សពាលនោះ ទើបក្ដៅ ឬឆេះដោយកម្មទាំងឡាយរបស់ខ្លួន ដូចភ្លើងឆេះព្រៃ ៚—

---

កត្តាន កុសលំ កម្មំ កត្តានាកុសលំ បុរេ
សុខិតំ ទុក្ខិតំ ហោន្តំ សោ ពាលោ យោ ន បស្សតិ

៙ កិរិយាដល់នូវសេចក្ដីសុខបាន ព្រោះតែធ្វើនូវកម្មជាកុសលទុកមុន, កិរិយាដល់នូវសេចក្ដីទុក្ខបាន ព្រោះតែធ្វើនូវកម្មជាអកុសលទុកមុន, អ្នកណា មិនឃើញដូច្នេះ អ្នកនោះជាមនុស្សពាល ៚—

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ពាលោធ បាបកំ កត្វា ន តំ ឆឌ្ឌិតុមុស្សហេ
កិំ ព្យគ្ឃអាទិ គប្ពត្តោ បទំ មក្ខេតុមុស្សហេ

៙ មនុស្សពាលក្នុងលោកនេះ ធ្វើអំពើអាក្រក់ ហើយមិនចេះព្យាយាម ដើម្បីនឹងលះអំពើអាក្រក់នោះចោលឡើយ, ដូចសត្វ មានខ្លាធំជាដើម កាលដែលទៅ មិនដែលព្យាយាមដើម្បីនឹងលុបស្នាមជើងឡើយ ៙

—៙—

យថា បុទម្ពរា បក្កា ពហិរត្តកមេវ ច
អន្តោកិមិលបូរណា ឯវំ ទុជ្ជនធម្មតា

៙ ផ្លែល្វាដែលទុំហើយ ខាងក្រៅមានពណ៌ក្រហមស្រស់ តែខាងក្នុង ពេញដោយសត្វមមង់ ដូចម្ដេចមិញ រីធម្មតារបស់មនុស្សទុរជន ក៏ដូច្នោះឯង ៙

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សុនខោ សុនខំ ទិស្វា ទន្តំ ទស្សេតិ ហឹសិតុំ
ទុជ្ជនោ ទុជ្ជនំ ទិស្វា រោសយំ ហឹសមិច្ឆតិ

៦ ឆ្កែឃើញឆ្កែផងគ្នា រមែងញេញធ្មេញបង្ហាញគ្នាដើម្បីនឹងបៀតបៀនគ្នា, មនុស្សទុរជន ឃើញមនុស្សទុរជនដូចគ្នា ក៏រមែងប្រាថ្នានូវសេចក្តីបៀតបៀនគ្នា ដែលកើតអំពីសេចក្តីក្រេវក្រោធ ៚

—๛๏๛—

មណ្ឌូកោបិ សីហោ វិយ កាកោ គណ្ឋោ បិយេបិយេ
ពាលោ ប បណ្ឌិតោ វិយ ធីរោ បុច្ឆេ ឯយេឯយេ

៧ សត្វកង្កែបអង្គុយធ្វើទំនងដូចសត្វសីហៈ កាលដែលក្អែកធាបចុះពឹក បានតែស្រែកថា "បិយបិយៈ", មនុស្សពាលលើកខ្លួនស្មើនឹងបណ្ឌិតដែលមានប្រាជ្ញា កាលបើភេនគេសួរអ្វី ១ ក៏ចេះតែនិយាយបត់បែ ឬបានតែទាងទទួលពាក្យថា "បាទ ៗ" ឬ "អើ ៗ" ប៉ុណ្ណោះ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# មិត្តភជា

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សត្ថោ បវសតោ មិត្តំ មាតា មិត្តំ សកេ ឃរេ
សហាយោ អត្ថជាតស្ស ហោតិ មិត្តំ បុនប្បុនំ
សយំ កតានិ បុញ្ញានិ តំ មិត្តំ សម្បរាយិកំ

៙ បក្ខពួក ជាមិត្ររបស់អ្នកដើរផ្លូវ, មាតា ជាមិត្រក្នុងផ្ទះរបស់ខ្លួន, អ្នកដែលមានចិត្តប្រព្រឹត្តទៅស្មើគ្នា ជាមិត្ររបស់អ្នកដែលមានធុរៈកើតឡើងរឿយៗ, បុណ្យទាំងឡាយដែលគេធ្វើដោយខ្លួនឯង ជាមិត្រតាមទៅក្នុងភពខាងមុខ ៕

សព្ភិរេវ សមាសេថ សព្ភិ កុព្ពេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សេយ្យោ ហោតិ ន បាបិយោ

៙ បុគ្គល គប្បីអង្គុយរួមជាមួយនឹងសប្បុរសតែម្យ៉ាង គប្បីធ្វើនូវសេចក្ដីស្និទ្ធស្នាលដោយពួកសប្បុរស, ព្រោះដឹងច្បាស់នូវព្រះសទ្ធម្មរបស់សប្បុរស រមែងមានតែសេចក្ដីល្អ មិនមានអាក្រក់ឡើយ ៕

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ បញ្ញំ លភតិ នាញ្ញតោ

៙ បុគ្គល គប្បីអង្គុយរួមជាមួយនឹងសប្បុរសតែម្យ៉ាង គប្បីធ្វើនូវសេចក្តីស្និទ្ធស្នាលដោយពួកសប្បុរស, ព្រោះដឹងច្បាស់នូវព្រះសទ្ធម្មរបស់សប្បុរស រមែងបាននូវប្រាជ្ញា, ប្រាជ្ញា គេមិនមែនបានអំពីទីដទៃឡើយ ៚—

—៚៙៚—

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សោកមជ្ឈេ ន សោចតិ

៙ បុគ្គល គប្បីអង្គុយរួមជាមួយនឹងសប្បុរសតែម្យ៉ាង គប្បីធ្វើនូវសេចក្តីស្និទ្ធស្នាលដោយពួកសប្បុរស, ព្រោះដឹងច្បាស់ នូវព្រះសទ្ធម្មរបស់សប្បុរស រមែងមិនសោកសៅ ក្នុងកណ្តាល នៃពួកជនអ្នកសោកសៅឡើយ ៚–

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ ញាតិមជ្ឈេ វិរោចតិ

៙ បុគ្គល គប្បីអង្គុយរួមជាមួយនឹងសប្បុរសតែម្យ៉ាង គប្បីធ្វើនូវសេចក្តីស្និទ្ធស្នាលដោយពួកសប្បុរស, ព្រោះដឹងច្បាស់ នូវព្រះសទ្ធម្មរបស់សប្បុរស រមែងរុងរឿងក្នុងកណ្តាលញាតិ ៚

—៚៙៚—

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សត្តា គច្ឆន្តិ សុគតឹ

៙ បុគ្គល គប្បីអង្គុយរួមជាមួយនឹងសប្បុរសតែម្យ៉ាង គប្បីធ្វើនូវសេចក្តីស្និទ្ធស្នាលដោយពួកសប្បុរស, ព្រោះដឹងច្បាស់នូវព្រះសទ្ធម្មរបស់សប្បុរស សត្វទាំងឡាយ រមែងទៅកាន់សុគតិ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ

តំ សទ្ធម្មមញ្ញាយ សត្តា តិដ្ឋន្តិ សាគតំ

គ្គល គប្បីអង្គុយរួមជាមួយនឹងសប្បុរសតែម្យ៉ាង គប្បីធ្វើនូវសេចក្ដី ភាលដោយពួកសប្បុរស, ព្រោះដឹងច្បាស់ នូវព្រះសទ្ធម្មរបស់ ស សត្វទាំងឡាយរមែងស្ថិតនៅបានសេចក្ដីសប្បាយយូរ ៙—

ព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ

តំ សទ្ធម្មមញ្ញាយ សព្វទុក្ខា បមុច្ចតិ

គ្គល គប្បីអង្គុយរួមជាមួយនឹងសប្បុរសតែម្យ៉ាង គប្បីធ្វើនូវសេចក្ដី ស្នាលដោយពួកសប្បុរស, ព្រោះដឹងច្បាស់ នូវព្រះសទ្ធម្មរបស់ សេ រមែងរួចចាកទុក្ខទាំងពួង ៙—

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ
ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ

ខ បុគ្គល មិនគប្បីសេពគប់នូវមិត្រដ៏លាមកទាំងឡាយឡើយ មិនគប្បីសេពគប់ នូវបុរសមានគំនិតថោកទាបទាំងឡាយឡើយ គប្បីសេពគប់តែនឹងកល្យាណមិត្រទាំងឡាយ គប្បីសេពគប់នូវបុរសដ៏ឧត្តមទាំងឡាយ ។

ពាលសង្គតចារី ហិ ទីឃមទ្ធាន សោចតិ
ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វទា
ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ

ខ មែនពិត បុគ្គលដែលប្រព្រឹត្តនៅរួមជាមួយនឹងមនុស្សពាល រមែងសោកសៅអស់កាលយូរ, កិរិយានៅជាមួយ នឹងមនុស្សពាលទាំងឡាយ រមែងនាំមកនូវសេចក្តីទុក្ខសព្វ ៗ កាល ដូចជាកិរិយានៅជាមួយនឹងមនុស្សជាសត្រូវ, កិរិយានៅជាមួយនឹងអ្នកប្រាជ្ញ រមែងនាំមកនូវសេចក្តីសុខ ដូចជាកិរិយានៅរួបរួមគ្នានៃញាតិទាំងឡាយ ៕—

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

វំ នេតិ ទុម្មេធោ អត្ថរាយំ និយុញ្ជតិ
ឃា សេយ្យសោ ហោតិ សម្មាវុត្តោបិ កុប្បតិ
សោ ន ជានាតិ សាធុ តស្ស អទស្សនំ

នុស្ស ឥតប្រាជ្ញា រមែងណែនាំនូវចំណែកដែលមិនគួរណែនាំ កនាំឲ្យប្រកបក្នុងចំណែកដែលមិនមែនជាធុរៈ ជាមនុស្សគឺគេណែ ដៅឲ្យល្អបានដោយលំបាក កាលបើគេនិយាយល្អៗ ក៏ស្រាប់តែ ខឹង, មនុស្សនោះមិនចេះដឹងវិន័យច្បាប់អ្វីឡើយ, កិរិយា ប្រទះ ឬមិនឃើញនូវមនុស្សដូចនោះ ជាការល្អ ៙—

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

នយំ នយតិ មេធាវី អធុរាយំ ន យុញ្ជតិ
សុនយោ សេយ្យសោ ហោតិ សម្មាវុត្តោ ន កុប្បតិ
វិនយំ សោ បជានាតិ សាធុ តេន សមាគមោ

៙ អ្នកប្រាជ្ញ តែងណែនាំនូវចំណែក ដែលគួរណែនាំ មិនដឹកនាំឲ្យប្រកបក្នុងចំណែក ដែលមិនមែនជាធុរៈឡើយ ជាមនុស្សដែលគេណែនាំឬប្រដៅឲ្យល្អបានដោយងាយ កាលបើគេនិយាយល្អៗ មិនខឹងក្រេវក្រោធ ទទឹងឡើយ, អ្នកប្រាជ្ញនោះ រមែងដឹងនូវវិន័យជាក់ច្បាស់ ការសេពគប់រួមមួយអន្លើដោយអ្នកប្រាជ្ញនោះ ជាការល្អប្រពៃ គឺថា ញុំាងប្រយោជន៍ឲ្យសម្រេចបាន ៕

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

អញ្ញទត្ថុហរោ មិត្តោ យោ ច មិត្តោ វចីបរោ
អនុប្បិយញ្ច យោ អាហ អបាយេសុ ច យោ សខា

៙ មិត្រណា ដែលគិតតែពីចង់បានទ្រព្យរបស់ អំពីមិត្រសំឡាញ់តែម្យ៉ាង, មិត្រណាដែលមានវាចាដ៏ក្រៃលែងគឺមិត្រល្អតែមាត់ មិត្រណាដែលប៉ិននិយាយប្រចុប គឺនិយាយអែបអបចាក់បណ្ដោយតាមមិនឲ្យទាស់ មិត្រណា ដែលជាសំឡាញ់នាំឲ្យវិនាស ៚

—៚៙៚—

ឯតេ អមិត្តេ ចត្តារោ ឥតិ វិញ្ញាយ បណ្ឌិតោ
អារកា បរិវជ្ជេយ្យ មគ្គំ បដិភយំ យថា

៙ អ្នកប្រាជ្ញ កាលបើបានដឹងច្បាស់នូវមិត្រទាំង៤នោះ ថាមិនមែនជាមិត្រពិតដូច្នោះហើយ គប្បីវៀរឲ្យឆ្ងាយចាកមិត្រទាំង ៤ នោះ ដូចជាអ្នកដំណើរដែលចៀសវាងផ្លូវប្រកបដោយភ័យ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ឧបការោ ច យោ មិត្តោ សុខទុក្ខោ ច យោ សខា

អត្ថក្ខាយី ច យោ មិត្តោ យោ ច មិត្តានុកម្បកោ

៙ មិត្រណា ជាអ្នកមានឧបការៈ សំឡាញ់ណា ជាអ្នករួមសុខរួមទុក្ខជាមួយគ្នា មិត្រណា ជាអ្នកណែនាំប្រាប់ប្រយោជន៍ មិត្រណា ជាអ្នកមានសេចក្ដីអនុគ្រោះ ៚

ឯតេបិ មិត្តេ ចត្តារោ ឥតិ វិញ្ញាយ បណ្ឌិតោ

សក្កច្ចំ បយិរុបាសេយ្យ មាតា បុត្តំវ ឱរសំ

៙ អ្នកប្រាជ្ញ កាលបើបានដឹងច្បាស់នូវមិត្រទាំងឡាយ ៤ ពួកនោះ ថាជាមិត្រពិតប្រាកដ ដូច្នោះហើយ គប្បីចូលទៅអង្គុយជិតនឹងមិត្រនោះ ដោយសេចក្ដីស្និទ្ធស្នាល ដូចជាមាតានឹងកូននោះចុះ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

រុក្ខោ សុភូមិនិស្សាយ បុប្ផផលំ បវឌ្ឍតិ
សប្បុរិសូបនិស្សាយ មហាបុញ្ញំ បវឌ្ឍតិ

គ ដើមឈើអាស្រ័យទីដីល្អ តែងមានផ្កា និងផ្លែចម្រើនឡើងល្អ, អ្នកដែលចូលទៅអាស្រ័យ នឹងសប្បុរស តែងមានសេចក្ដីល្អចម្រើនឡើងយ៉ាងពិត ៚

អហិតេ បដិសេធោ ច ហិតេសុ ច និយោជកោ
ព្យសនេ ចាបរិច្ចាគោ សង្ខេបំ មិត្តលក្ខណំ

ឃ កិរិយាហាមគ្នាក្នុងការដែលមិនមែនប្រយោជន៍ កិរិយាដឹកនាំគ្នាឲ្យប្រកបក្នុងការដែលជាប្រយោជន៍ កិរិយាមិនលះចោលគ្នាក្នុងកាលដែលកើតការក្រ នេះជាលក្ខណៈរបស់មិត្រ ដោយសង្ខេប ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ហិតេសនោ សុមិត្តោ ច វិញ្ញូ ច ទុល្លភោ ជនោ

យថោសធញ្ច សាធុញ្ច រោគហារី ច សជ្ជនោ

ក៏ ជនដែលស្វែងរកប្រយោជន៍ ជាមិត្រសំឡាញ់ដ៏ល្អផង ជាអ្នកប្រាជ្ញផង នេះ គេរកបានដោយកម្រណាស់ ដូចជាថ្នាំសម្រាប់រម្ងាប់រោគ ដែលមានរសឆ្ងាញ់ផង អាចបំបាត់រោគបានផង ថ្នាំនោះ គេរកបានដោយកម្រដូចគ្នា ៕—

—៚៙៚—

លុទ្ធមត្ថេន គណ្ហេយ្យ ថទ្ធមញ្ជលិកម្មុនា

ឆន្ទានុវត្តិយា មូឡ្ហំ យថាភូតេន បណ្ឌិតំ

៙ គប្បីយកចិត្តមនុស្សលោភ ដោយចែកប្រយោជន៍ឲ្យ មនុស្សរឹងរូស ដោយអញ្ជលីកម្ម មនុស្សល្ងង់ ដោយបណ្ដោយតាមចិត្ត តែឯអ្នកប្រាជ្ញ ត្រូវធ្វើតាមសេចក្ដីពិត ៕—

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ហិតំ ករោ បរោ ពន្ធុ ពន្ធុបិ អហិតោ បរោ

អហិតោ ទេហជោ ព្យាធិ ហិតមារញ្ញមោសធំ

៙ អ្នកឯទៀតធ្វើប្រយោជន៍ឲ្យ ក៏ដូចជាផៅពង្ស. ចំណែកខាងផៅពង្ស ដែលមិនធ្វើប្រយោជន៍ឲ្យ ក៏ដូចអ្នកឯទៀតវិញ. ព្យាធិដែលកើតក្នុងកាយ ជារបស់ឥតប្រយោជន៍ ចំណែកថ្នាំដែលកើតក្នុងព្រៃ ក៏ត្រឡប់ទៅជាកេនប្រយោជន៍វិញបាន ៚

—៚៙៚—

បទុមំវ មុខំ យស្ស វាចា ចន្ទនសីតលំ

មធុ តិដ្ឋតិ ជិវ្ហគ្គេ ហទយេ សុហាលាហលំ

តាទិសំ នោ បសេវេយ្យ តំ មិត្តំ បរិវជ្ជយេ

៙ អ្នកណាមានមុខរីកដូចផ្កាឈូក មានវាចាត្រជាក់ដូចខ្លឹមចន្ទន៍ហើយ អ្នកនោះមានទឹកឃ្មុំនៅចុងអណ្ដាត តែក្នុងចិត្តប្រឡាក់ទៅដោយថ្នាំពិសដ៏ខ្លាំង បុគ្គល មិនគួរសេពគប់នឹងមនុស្សដូចនោះឡើយ គប្បីវៀរនូវមិត្រនោះចេញ ៚

មូឡ្ហសិស្សោបទេសេន កុនារី សរណេន ច
ទលេសត្តហិ សំយោគា បណ្ឌិតោបិ បសីទតិ

៙ សូម្បីជាអ្នកប្រាជ្ញ ក៏គង់ធ្លាក់ខ្លួនចុះ ព្រោះហេតុដែលប្រដៅឲ្យកាន់ការទំនៀមទំលាប់ ដល់សិស្សល្ងង់ ព្រោះមានស្ត្រីអាក្រក់ជាទីពំនាក់ ព្រោះប្រកបដោយសត្រូវគឺមនុស្សខ្លៅ ៚

អសតំ សម្បយោគេន សន្តោបិ អសន្តោ ភវេ
មគ្គោ កបរិយុត្តោ ឧជុម្បិ អសាធុ ភវេ

៙ សូម្បីសប្បុរស ក៏ត្រឡប់ទៅជាអសប្បុរសបាន ដោយកិរិយាគប់រក ជាមួយនឹងអសប្បុរស ប្រៀបដូចជាផ្លូវថ្នល់ ដែលដេរដាសពេញពាស ដោយសម្រាម, ផ្លូវនោះ បើទុកជាត្រង់ ក៏មិនល្អ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ឧស្សាហោ រិបុវ មិត្តំ អលសោ មិត្តវ រិបុ
វិសំ វិយាមតំ វិជ្ជា បមាទោ អមតំ វិសំ

៙ សេចក្ដីឧស្សាហ៍ព្យាយាម ហាក់ដូចជាសត្រូវ តែត្រឡប់មកជាមិត្រ, សេចក្ដីខ្ជិល ហាក់ដូចជាមិត្រ តែត្រឡប់មកជាសត្រូវ, វិជ្ជាហាក់ដូចជាពិស តែឈ្មោះថាមិនស្លាប់, សេចក្ដីប្រមាទ ហាក់ដូចជាមិនស្លាប់ដែរ តែត្រឡប់ក្លាយទៅជាពិសវិញ ។៚–

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

# បណ្ឌិតភថា

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

មុហុត្តមបិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ
ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា

៙ វិញ្ញូជនគឺជនអ្នកដឹង បើចូលទៅអង្គុយជិតអ្នកប្រាជ្ញសូម្បីមួយរំពេច រមែងចេះដឹងនូវធម៌អំពី ដោយឆាប់រហ័ស ដូចគ្នានឹងអណ្ដាតដែលដឹងនូវរសនៃសម្ល ៕—

ភទ្រាបិ បស្សតិ បាបំ យាវ ភទ្រំ ន បច្ចតិ
យទា ច បច្ចតី ភទ្រំ អថ ភទ្រានិ បស្សតិ

៙ អំពើល្អមិនទាន់ឲ្យនូវផលត្រឹមណា មនុស្សល្អក៏នៅតែឃើញតែបាប ត្រឹមនោះ. លុះតែកាលណាកដល់អំពើល្អឲ្យផល មនុស្សល្អទើបឃើញ នូវអំពើល្អ ក្នុងកាលនោះ ៕—

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

មាវមញ្ញេថ បុញ្ញស្ស ន មត្តំ អាគមិស្សតិ

ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ

បូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកម្បិ អាចិនំ

២ បុគ្គលកុំគប្បីមើលងាយនូវបុណ្យ ថាបុណ្យបន្តិចបន្តួច នឹងមិនមកដល់គឺថានឹងមិនឲ្យផលឡើយ សូម្បីក្អមទឹក រមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ, អ្នកមានប្រាជ្ញា កាលដែលសន្សំនូវបុណ្យបន្តិចម្ដងៗ ក៏គង់ពេញដោយបុណ្យបាន ៚—

—~~~—

និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ

និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ

តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ

៣ បុគ្គល គួរឃើញនូវអ្នកប្រាជ្ញណា ដែលមានប្រាជ្ញាពោលសង្កត់សង្កិនចង្អុលប្រាប់ទោសឲ្យឃើញ ដូចជាមនុស្សដែលជាអ្នកប្រាប់កំណប់ទ្រព្យ គួរគប់នូវអ្នកប្រាជ្ញប្រាកដដូច្នោះ, កាលបើបុគ្គលគប់នូវអ្នកប្រាជ្ញដូច្នោះហើយ រមែងបានគុណដ៏ប្រសើរ ឥតមានទោសដ៏លាមកឡើយ ៚-

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ឱវទេយ្យានុសាសេយ្យ

អសព្ភា ច និវារយេ

សតំ ហិ សោ បិយោ ហោតិ

អសតំ ហោតិ អប្បិយោ

៙ បណ្ឌិត គួរទូន្មាន គួរប្រៀនប្រដៅ ទាំងគួរហាមឃាត់ នូវជនទាំងឡាយ ចាកកិរិយាពោលរបស់អសប្បុរស គឺអកុសលធម៌, បណ្ឌិតនោះ បានជាទីស្រឡាញ់ របស់សប្បុរសទាំងឡាយដោយពិត តែមិនជាទីស្រឡាញ់នៃអសប្បុរសទាំងឡាយឡើយ ៕

ធម្មបីតិ សុខំ សេតិ វិប្បសន្នេន ចេតសា

អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ

៙ បណ្ឌិត ដែលមានបីតិ គឺសេចក្តីរីករាយក្នុងធម៌ មានចិត្តជ្រះថ្លា ហើយត្រេកអររាល់វេលា ក្នុងធម៌ដែលព្រះអរិយៈសម្តែងហើយ តែងដេកនៅជាសុខ ៕

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

ទុល្លភោ បុរិសាជញ្ញោ ន សោ សព្វត្ថ ជាយតិ
យត្ថ សោ ជាយតី ធីរោ តំ កុលំ សុខមេធតិ

៙ បុរសអាជានេយ្យ គេរមែងស្វែងរកបានដោយកម្រ, បុរសនោះមិនដែលកើតសព្វប្រទេសឡើយ, អ្នកប្រាជ្ញមានប្រាជ្ញា កាលបើកើតក្នុងត្រកូលណា រមែងញ៉ាំងត្រកូលនោះ ឲ្យដល់នូវសេចក្តីសុខ ៚

ន តេន បណ្ឌិតោ ហោតិ យាវតា ពហុ ភាសតិ
ខេមី អវេរី អភយោ បណ្ឌិតោតិ បវុច្ចតិ

៙ បុគ្គល និយាយច្រើន ដោយហេតុមានប្រមាណប៉ុន្មាន មិនឈ្មោះថាជាបណ្ឌិត ដោយហេតុមានប្រមាណប៉ុន្មាននោះក៏ទេ, អ្នកដែលមានសេចក្តីក្សេម ដែលមិនមានពៀរ ដែលមិនមានភ័យ ព្រះមានព្រះភាគឲ្យឈ្មោះហៅថាជាបណ្ឌិត ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

យថា ច បនសា បក្កា ពហិកណ្ដកមេវ ច
អន្ដោ អមតបូរណា ឯវំ សុជនធម្មតា

៙ ផ្លែខ្នុរទុំ ខាងក្រៅជាសពាសដោយបន្លា តែខាងក្នុងពេញដោយទឹកជា-
រសដូចអម្រឹត ដូចម្ដេចមិញ ធម្មតារបស់ជនល្អ ក៏ដូចនោះឯង ៚

---

អម្ពុំ បិវន្តិ នោ នជ្ជោ រុក្ខា ខាទន្តិ នោ ផលំ
មេឃោ កទាចិ នោ សស្សំ បរត្ថាយ សតំ ធនំ

៙ ស្ទឹងទាំងឡាយ មិនដែលផឹកទឹកខ្លួនឯងឡើយ, ដើមឈើមិនដែលស៊ីផ្លែខ្លួនឯងឡើយ, ទឹកភ្លៀងដែលធ្លាក់ចុះមិនដែលស៊ីស្រូវខ្លួន ក្នុងកាលណាម្ដងឡើយ, ទ្រព្យរបស់សាធុជនទាំងឡាយ ក៏ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់អ្នកដទៃ ដូចនោះ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org

បាបមិត្តេ វិវជ្ជេត្វា ភជេយ្យុត្តមបុគ្គលំ

ឱវាទេ បស្ស តិដ្ឋេយ្យ បត្ថេន្តោ អចលំ សុខំ

៙ បុគ្គល កាលបើប្រាថ្នានូវសេចក្តីសុខមិនឲ្យមានកម្រើក គប្បីវៀរនូវមិត្រដ៏លាមកទាំងឡាយ ហើយគួរគប់នឹងបុគ្គលដ៏ឧត្តម ទាំងគួរតម្កល់នៅក្នុងឱវាទរបស់បុគ្គលដ៏ឧត្តមនោះ ៚

www.budinst.gov.kh www.elibraryofcambodia.org
www.elibraryofcambodia.org